# សុន្ទរកថា

## របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## សម្រាប់សន្និសីទសារព័ត៌មានរួមគ្នា ដោយសហប្រធានដឹកនាំកិច្ចប្រជុំកំពូល
## នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី ២
## ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៨, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

- **ឯកឧត្ដមសហប្រធាន,**
- **អ្នកសារព័ត៌មាន ជាទីរាប់អាន !**

ព្រឹត្តិការណ៍ថ្ងៃនេះ ត្រូវបានគួសចំណាំជាព្រឹត្តិការណ៍ប្រកបដោយអត្ថន័យជ្រាលជ្រៅជាប្រវត្តិសាស្ត្រមួយ ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី ២ ក្រោមមូលបទ : **«ទន្លេនៃសន្តិភាព និង ការអភិវឌ្ឍប្រកបដោយចីរភាព»** ។ ជាការពិតណាស់, ខ្ញុំពិតជាមានក្ដីសោមនស្ស ដោយបានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំនេះ ជាមួយសហសេវិកគួរជាទីគោរពរាប់អាន គឺ ឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ហើយក៏សូមប្រកាសដោយរីករាយថា កិច្ចប្រជុំនេះបានបញ្ចប់ប្រកបដោយជោគជ័យ ជាមួយនឹងលទ្ធផលជាទីពេញចិត្ត ។

កិច្ចប្រជុំថ្ងៃនេះ បានពិនិត្យឡើងវិញនូវវឌ្ឍនភាព ដែលសម្រេចបានចាប់តាំងពីកិច្ចប្រជុំកំពូលលើកទី ១ នៅទីក្រុងសានយ៉ា, សាធារណរដ្ឋប្រជាមានិតចិន កាលពីខែ មីនា ឆ្នាំ ២០១៦ កន្លងទៅ ។ នៅក្នុងថេរវេលាមិន ដល់ ២ ឆ្នាំផង យើងបានជំរុញយន្តការអនុតំបន់ថ្មីនេះ ទៅជាគម្រោងកិច្ចសហប្រតិបត្តិការពេញលេញមួយ ។

ចំពោះសមត្ថភាពស្ថាប័ន, យើងអាចកសាងបាននូវរចនាសម្ព័ន្ធប្រតិបត្តិការងារពហុស្រទាប់ និង យន្តការអនុវត្តដែលមានលក្ខណៈរឹងមាំ និង ពេញលេញ ហើយយើងក៏មានទំនុកចិត្តយ៉ាងមុតមាំថា យន្តការទាំងនេះ នឹងជំរុញឱ្យប្រទេសជាសមាជិកទាំង ៦ អាចធ្វើដំណើរបានកាន់តែលឿនឆ្ពោះទៅរកសម្រេចគោលដៅនៃការប្រែក្លាយកិច្ចសហប្រតិបត្តិការមេគង្គ- ឡានឆាង ជាសហគមន៍មួយដែលមានអនាគត, សន្តិភាព និង វិបុលភាពរួមគ្នា ។

ក្នុងចំណោមបណ្ដាយន្តការនានា, យើងបានបង្កើតឡើងនូវលេខាធិការដ្ឋាន/អង្គភាពសម្របសម្រួលថ្នាក់ជាតិ នៅក្នុងប្រទេសជាសមាជិកទាំង ៦ និង បានជំរុញក្រុមការងាររួមសម្រាប់វិស័យអាទិភាពសំខាន់ៗនៃសហ-ប្រតិបត្តិការ ឱ្យមានសកម្មភាពរស់រវើក ។ បណ្ដាស្ថាប័នមួយចំនួនផ្សេងទៀត ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីជួយគាំទ្រដល់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង រួមមានជាអាទិ៍ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹក, មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការបរិស្ថានមេគង្គ- ឡានឆាង និង មជ្ឈមណ្ឌលសិក្សាទន្លេមេគង្គសាកល ។

យើងក៏សម្ដែងសេចក្ដីសោមនស្សរីករាយផងដែរ ចំពោះវឌ្ឍនភាពជាសារវន្តដែលសម្រេចបាននៅក្នុងការ-អនុវត្តបញ្ជីរួមនៃគម្រោងឆាប់ទទួលបានផលភ្លាមៗទាំង ៤៥ ដែលត្រូវបានកំណត់ក្នុងកិច្ចប្រជុំកំពូលនៃកិច្ចសហ-ប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី ១ និង គំនិតផ្ដួចផ្ដើម ១៣ ផ្សេងទៀត ដែលសាធារណរដ្ឋប្រជាមានិតចិន បានដាក់ស្នើ នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី ២ ។

ក្រោមការដាក់ចេញឱ្យអនុវត្តមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង របស់សាធារណ-រដ្ឋប្រជាមានិតចិន ដើម្បីទ្រទ្រង់បណ្ដាគម្រោងខ្នាតតូច និង មធ្យម, យើងបានកត់សម្គាល់ប្រកបដោយក្ដីសោមនស្ស និង

ពេញចិត្ត ថា គម្រោងទាំង ១៣២ ស្ថិតក្នុងក្រុមគម្រោងដំណាក់កាលទី ១ ដែលទ្រទ្រង់ដោយមូលនិធិពិសេស កិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ ២០១៧ ត្រូវបានអនុវត្តជាលំដាប់យ៉ាងខ្ជាប់ខ្ជួន ។

ដោយបន្ថែមលើចលនការរកលូតលាស់ប្រសើរនេះ, ក្នុងកិចប្រជុំថ្ងៃនេះ, ពួកយើងឈានដល់ការសម្រេចបាននូវកុងសង់ស៊ុស និង អនុម័តឯកសារសំខាន់ៗចំនួន ២ គឺ (១)-សេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញនៃកិចប្រជុំថ្នាក់ដឹកនាំនៃកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី ២, និង (២)-ផែនការសកម្មភាពប្រាំឆ្នាំនៃកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០១៨-២០២២) ។ យើងក៏បានកត់សម្គាល់នូវបណ្តាគម្រោងដំណាក់កាលទី ២ ដែលទ្រទ្រង់ដោយមូលនិធិពិសេសកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ ២០១៨ និង របាយការណ៍វឌ្ឍនភាពរបស់ក្រុមការងាររួមទាំង ៦ តាមវិស័យអាទិភាពសំខាន់ៗ ។

ជាសរុបមក, យើងមានមោទនភាពចំពោះរាល់សមិទ្ធិផលសម្រេចបានជាក់ស្តែង ហើយក៏ទន្ទឹងមើលប្រកបដោយសុទិដ្ឋិនិយមខ្ពស់ ចំពោះអនាគតនៃកិចសហប្រតិបត្តិការមេគង្គ-ឡានឆាងនេះ ។ ជាមួយនឹងការកត់សម្គាល់ទាំងនេះ, ខ្ញុំក៏សូមផ្តល់ជាព័ត៌មានថា កម្ពុជាបានបញ្ចប់អណត្តិភាពជាសហប្រធានរយៈពេល ២ ឆ្នាំ ជាមួយសាធារណរដ្ឋប្រជាមានិតចិនដែលជាសហប្រធានអចិន្ត្រៃយ៍ ហើយថ្ងៃនេះ ខ្ញុំបានប្រគល់អណត្តិភាពជាសហប្រធានទៅកាន់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវវិញម្តង ។

ជាចុងក្រោយ, តាងនាមឱ្យសហសេវិកទន្លេមេគង្គទាំងអស់, ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណដល់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ចំពោះតួនាទីដឹកនាំក្នុងការពន្លឿនរបៀបវារៈកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ក៏ដូចជាចំពោះការគាំទ្រឥតងាករេលើភាពជាសហប្រធានរបស់កម្ពុជា ក្នុងកំឡុងពេល ២ ឆ្នាំកន្លងមកនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់ ហើយសូមផ្តល់វេទិការនេះទៅកាន់សហប្រធានរបស់ខ្ញុំ ដើម្បីចែករំលែកមតិយោបល់ !